# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

## សេចក្តីជូនដំណឹង
## ស្តីពី
## ការផ្អាកការពិនិត្យកាយសម្បទាដោយផ្ទាល់នៅនាយកដ្ឋានពេទ្យការងារ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនម្ចាស់ ឬនាយករោងចក្រ សហគ្រាស និងកម្មករនិយោជិត មេត្តាជ្រាបថា ដើម្បីចូលរួមចំណែកទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ នៅតាមរោងចក្រ សហគ្រាស ក្នុងអំឡុងពេលព្រឹត្តិការណ៍សហគមន៍-២០កុម្ភៈ នេះ ក្រសួងសម្រេចផ្អាកការពិនិត្យកាយសម្បទាដោយផ្ទាល់នៅនាយកដ្ឋានពេទ្យការងារ ចាប់ពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២១ តទៅ រហូតដល់មានការជូនដំណឹងជាថ្មី។

ម្ចាស់ ឬនាយករោងចក្រ សហគ្រាស និងកម្មករនិយោជិតទាំងអស់ អាចទៅពិនិត្យសុខភាពនៅតាមមូលដ្ឋានសុខាភិបាលដៃគូរបស់នាយកដ្ឋានពេទ្យការងារ រួចស្នើសុំការបញ្ជាក់វិញ្ញាបនបត្រពិនិត្យកាយសម្បទាពីនាយកដ្ឋានពេទ្យការងារតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម តាមរយៈគេហទំព័រ https://lacms.mlvt.gov.kh ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម ម្ចាស់ ឬនាយករោងចក្រ សហគ្រាស និងកម្មករនិយោជិតទាំងអស់ ជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តសេចក្តីជូនដំណឹងនេះឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃអង្គារ ១២កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៩៣ ៧៥ និងទូរសារ:(០២៣) ៨៨ ២៧ ៦៩